**SWIS-H**
STATEWIDE INFANT SCREENING - HEARING

# ហេតុអ្វីបានជាទារករបស់ខ្ញុំត្រូវការការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ



ប្រសិនបើទារករបស់អ្នកពុំបានទទួលលទ្ធផលច្បាស់លាស់ណាមួយ ពីការពិនិត្យមើលសោតវិញ្ញាណលើកដំបូងទាំងពីរដងនោះទេ គេនឹងត្រូវការការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ។

អាចមានមូលហេតុមួយចំនួនចំពោះករណីនេះ។ គឺថាវាអាចៈ

- មានវត្ថុរាវ ឬការរាំងខ្ទប់ក្នុងត្រចៀករបស់ទារកអ្នកក្រោយពេលកើតមក
- ទារករបស់អ្នកអាចមានកំរិតនៃការបាត់បង់សោតវិញ្ញាណមួយចំនួន។

ជាការសំខាន់ដែលអ្នកត្រូវស្វែងយល់ឲ្យបានដឹងយ៉ាងឆាប់ តាមលទ្ធភាពអាចធ្វើទៅបានថាតើទារករបស់អ្នកស្តាប់ឮល្អយ៉ាងណាដែរ ដើម្បីឲ្យអ្នក ហើយនិងទារករបស់អ្នកអាចទទួលបានឱវាទ និងការផ្គត់ផ្គង់ត្រឹមត្រូវ។

ប្រសិនបើអ្នករស់នៅឆ្ងាយជាង១០០គីឡូម៉ែត្រ ពីមន្ទីរពេទ្យដែលគេបានបញ្ជូនអ្នក សូមសាកសួរបុគ្គលដែលផ្តល់កូនសៀវភៅព័ត៌មាននេះមកអ្នក ដើម្បីទទួលព័ត៌មានអំពីគ្រោងការណ៍ជំនួយលើការធ្វើដំណើរ SWIS-H។

## តើនឹងមានអ្វីកើតឡើងនៅកន្លែងវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ?

តេស្តមួយចំនួននឹងបានធ្វើឡើង ដើម្បីផ្តល់ព័ត៌មានលំអិតថាតើទារករបស់អ្នកស្តាប់ឮយ៉ាងណាដែរ។

គ្រូពេទ្យសោតវិញ្ញាណដែលជាអ្នកឯកទេសក្នុងការធ្វើតេស្តសោតវិញ្ញាណ នឹងចាត់ចែងការធ្វើតេស្ត។ ការវាយតម្លៃនេះឥតគិតថ្លៃឡើយ។

ពុំមានតេស្តណាមួយនឹងធ្វើឲ្យទារករបស់អ្នកឈឺចាប់ឡើយ។

## តើខ្ញុំត្រៀមរៀបចំទារករបស់ខ្ញុំសម្រាប់ការវាយតម្លៃដោយរបៀបណា?

ជាការប្រសើរបំផុត ប្រសិនបើទារករបស់អ្នកគេងលក់ក្នុងអំឡុងពេលធ្វើតេស្តទាំងនោះ។ ដោយហេតុនេះ ជាការមានប្រយោជន៍ដែលអ្នកគួរអញ្ជើញមកឲ្យបានមុនពេលបន្តិច ដើម្បីឲ្យអ្នកមានពេលបំបៅ និងដាក់ទារករបស់អ្នកឲ្យគេងលក់ដោយស្ងប់ស្រួល។

ប្រសិនបើអ្នកមានកូនដទៃទៀត សូមរៀបចំឲ្យមាននរណាម្នាក់ជួយមើលថែគេនៅផ្ទះ ដើម្បីឲ្យអ្នកអាចនៅជាមួយទារករបស់អ្នក រហូតដល់ចប់ការវាយតម្លៃ។ បរិដ្ឋានត្រូវតែរក្សាការស្ងាត់ស្ងៀម។

ដោយហេតុថាការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណ រួមមានការធ្វើតេស្តផ្សេងៗមួយចំនួន ដូច្នេះសូមត្រៀមទុកពេលមួយព្រឹក ឬក៏មួយរសៀល ដោយអាស្រ័យទៅលើពេលណាត់ជួបរបស់អ្នកដែលបានកំណត់។ អ្នកប្រហែលជាចង់នាំអ្នកជួយផ្គត់ផ្គង់មកជាមួយអ្នកដែរ។

## តើការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណត្រូវធ្វើឡើងដោយរបៀបណា?

ការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណនេះហៅថា ការធ្វើតេស្ត Auditory Brainstem Response (ABR) (ការធ្វើតេស្តឲ្យមានការឆ្លើយតបពីទងខួរក្បាលទៅនឹងសូរសម្លេង)។ គេនឹងដាក់គ្រឿងប្រដាប់ទទួលសញ្ញាស្រដៀងគ្នានឹងគ្រឿងប្រដាប់ដែលប្រើក្នុងការពិនិត្យមើលសោតវិញ្ញាណ ទៅលើក្បាលទារករបស់អ្នក។ គេនឹងចាក់សូរសម្លេង តាមរយៈឧបករណ៍សម្រាប់ពាក់ស្តាប់សម្លេងនៅលើក្បាលទារករបស់អ្នក។ ការឆ្លើយតបរបស់ទារកអ្នកទៅនឹងសូរសម្លេងត្រូវបានគេកត់ត្រាទុក។ ការឆ្លើយតបទាំងនេះបង្ហាញឲ្យដឹងនូវសម្លេងស្រាលបំផុតដែលទារករបស់អ្នកអាចស្តាប់ឮ។

## តើនឹងមានអ្វីកើតឡើងបន្ទាប់ពីការវាយតម្លៃ?

គ្រូពេទ្យសោតវិញ្ញាណនឹងអាចផ្តល់ព័ត៌មានជូនអ្នកអំពីលទ្ធផល ហើយពន្យល់អំពីអត្ថន័យនៃលទ្ធផលទាំងនោះ តាមធម្មតាការនេះធ្វើឡើងក្នុងថ្ងៃជាមួយគ្នា។

ប្រសិនបើទារករបស់អ្នកត្រូវបានគេរកឃើញថា មានការបាត់បង់សោតវិញ្ញាណ គេនឹងបញ្ជូនអ្នកទៅកាន់សេវាកម្មឯកទេសក្នុងមន្ទីរពេទ្យណាមួយ នៃមន្ទីរពេទ្យកុមាររដ្ឋ NSW បី ក្នុងរដ្ឋ NSW។ គេនឹងបញ្ជូនរបាយការណ៍មួយទៅឲ្យសេវាកម្មទាំងនេះ។ ដោយមានការយល់ព្រមពីអ្នក វេជ្ជបណ្ឌិតរបស់អ្នកក្នុងតំបន់ ហើយនិងគ្រូពេទ្យព្យាបាលរោគកូនក្មេងរបស់ទារកអ្នក នឹងបានទទួលសំណៅរបាយការណ៍មួយច្បាប់ផងដែរ។ គ្រូពេទ្យសោតវិញ្ញាណ និងភ្នាក់ងារសង្គមកិច្ចនឹងជួយអ្នកដើម្បីឲ្យទទួលបានសេវាកម្មទាំងឡាយ និងការផ្គត់ផ្គង់ដែលអ្នកនិងទារករបស់អ្នកអាចត្រូវការ។

ប្រសិនបើគេរកឃើញថាទារករបស់អ្នកមានសោតវិញ្ញាណធម្មតា ក៏ប៉ុន្តែដំណាក់កាលក្រោយមកស្រាប់តែអ្នកមានកង្វល់អំពីសោតវិញ្ញាណ ការលូតលាស់ផ្នែកនិយាយស្តី និងភាសារបស់ទារកអ្នក សូមរៀបចំឲ្យមានការធ្វើតេស្តសោតវិញ្ញាណរបស់ទារកអ្នកម្តងទៀត។

ការនិយាយទៅកាន់វេជ្ជបណ្ឌិតប្រចាំគ្រួសារអ្នក គឺជាកន្លែងចាប់ផ្តើមមួយដ៏ល្អ។ ការធ្វើតេស្តសោតវិញ្ញាណអាចធ្វើបាននៅគ្រប់អាយុ។

### សម្រាប់ព័ត៌មានបន្ថែម
### សូមបើកចូលវ៉ិបសាយខាងក្រោមនេះ៖

http://www.health.nsw.gov.au/kids-families

ការទាក់ទងក្នុងតំបន់ / ព័ត៌មានលំអិតអំពីការណាត់ជួប

សម្រាប់ឱវាទផ្នែកសុខភាព សូមទាក់ទង *healthdirect Australia*
http://www.healthdirect.gov.au/
**1800 022 222**

NSW GOVERNMENT | Health

© NSW Health September 2016 SHPN (NKF)150225